International Labour Organization

better factories Cambodia

# ឧស្សាហកម្មកាត់ដេរកម្ពុជាទើបងើបឡើងវិញពីឱនភាពសេដ្ឋកិច្ចជាសកល

## ការចាប់ផ្ដើមស្ដារឡើងវិញ

នៅក្នុងឆ្នាំ ២០១០ សេដ្ឋកិច្ចពិភពលោកបានបោះជំហានយ៉ាងខ្លាំងឈានទៅរកការស្ដារឡើងវិញជាសកល។ ការស្ដារឡើងវិញនូវសេដ្ឋកិច្ចនៅតាមប្រទេសអភិវឌ្ឍបានជម្រុញឱ្យមានការងើបឡើងវិញ នៃឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌ។ ឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា ដែលជាប្រទេសមួយក្នុងចំណោមប្រទេសនានាដែលទទួលរងផលប៉ះពាល់ជាអវិជ្ជមានជាងគេ នៅក្នុងរយៈពេលនៃឱនភាពនេះ[១] មានស្ថិរភាព និងមានកំណើននៅក្នុងឆ្នាំ ២០១០។ ការនាំចេញទៅកាន់សហរដ្ឋអាមេរិច ដែលជាប្រទេសនាំចូលធំជាងគេរបស់ឧស្សាហកម្មនេះ បង្ហាញថា ប្រទេសកម្ពុជាអាចងើបឡើងវិញបានលឿន ធៀបជាមួយនឹងប្រទេសដែលជាគូប្រកួតប្រជែងរបស់ខ្លួន (សូមមើលរូបភាពទី ១)។

រូបភាពទី ១: ការនាំចូលសម្លៀកបំពាក់របស់សហរដ្ឋអាមេរិច បែងចែកទៅតាមប្រទេស ពីខែ ធ្នូ ឆ្នាំ ២០០៩ ដល់ ខែ ធ្នូ ឆ្នាំ ២០១០ (%នៃការផ្លាស់ប្ដូរ)[២]




## ផលប៉ះពាល់សង្គម

ឧស្សាហកម្មកាត់ដេរបន្តជាអ្នករួមចំណែកដ៏ធំមួយ ចំពោះការនាំចេញ និងការបង្កើតការងារ នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា: ឧស្សាហកម្មនេះតំណាងឱ្យប្រមាណ ៩០% នៃការនាំចេញសរុប និងបានផ្ដល់ការងារដល់កម្មករនិយោជិតជាង ៣០០០០០ នាក់។ ឧស្សាហកម្មនេះបានទទួលរងឱនភាពយ៉ាងគំហុកមួយ ប៉ុន្តែបានងើបឡើងវិញ នៅក្នុងឆ្នាំ ២០១០ ដោយវិស័យនេះមានការកើនឡើងចំនួន ២៦% ហើយផលិតកម្មបានឈានមកដល់កម្រិតមុនពេលមានវិបត្តិវិញ (សូមមើលរូបភាពទី ២)។[៣] ទិន្នន័យប្រចាំខែ បង្ហាញថាកំណើនខ្ពស់បំផុត មាននៅក្នុងឆមាសទី ២ (សូមមើលរូបភាពទី ៥ និងទី ៦)។

រូបភាពទី ២: ការនាំចេញសម្លៀកបំពាក់របស់ប្រទេសកម្ពុជា ២០០១-២០១០ (គិតជាលានដុល្លារ)[៤]




ឆ្លើយតបទៅនឹងកំណើនថេរផ្នែកផលិតកម្មនេះ ចំនួនរោងចក្រដំណើរការមានការកើនឡើង: នៅក្នុងខែ ធ្នូ ឆ្នាំ ២០១០ មានរោងចក្រដំណើរការចំនួន ២៦២ បើធៀបជាមួយនឹង ២៤៣ នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៩។ ចំនួនរោងចក្រជាមធ្យមប្រចាំឆ្នាំមានការថយចុះ ប៉ុន្តែចំនួនរោងចក្រនៅក្នុងត្រីមាសចុងក្រោយមានការកើនឡើង (សូមមើលរូបភាពទី ៣ និងទី ៥)។ ប៉ុន្តែ ចំនួនរោងចក្រតូចៗមានការថយចុះ : កាលពីមុន មានរោងចក្រចំនួន

[១] "ការនាំចេញសម្លៀកបំពាក់បន្តមានការថយចុះ នៅក្នុងខែ សីហា ចំនួន ១៩%" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១០។

[២] ក្រសួងពាណិជ្ជកម្មសហរដ្ឋអាមេរិច ២០១០: រដ្ឋបាលពាណិជ្ជកម្មអន្តរជាតិ, ការិយាល័យវាយនភ័ណ្ឌ និងសម្លៀកបំពាក់ (http://otexa.ita.doc.gov/MSRCTRY.htm, ចូលមើលថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១១)

[៣] ក្រសួងពាណិជ្ជកម្ម ២០១១

[៤] ក្រសួងពាណិជ្ជកម្ម ២០១១

២៩% ដែលមានកម្មករនិយោជិតក្រោម ៥០០ នាក់ ប៉ុន្តែ ចំនួននេះបានថយចុះមកនៅត្រឹម ២១% នៅចុងឆ្នាំ ២០១០។[៥] រោងចក្រតូចៗ គឺជារោងចក្រដែលងាយរងគ្រោះជាងគេ នៅក្នុងកំឡុងពេលឱនភាពសេដ្ឋកិច្ចនេះ។

រូបភាពទី ៣: ចំនួនរោងចក្រ ២០០០-២០១០ (ចំនួនមធ្យមប្រចាំឆ្នាំ)[៦]




ខណៈពេលដែលផលិតកម្ម បានឈានដល់កម្រិតមុនវិបត្តិកើតមានឡើង, ចំនួនការងារមិនបានវិលមករកភាពដើមនោះទេ (សូមមើលរូបភាពទី ៤)។ ចំនួនការងារមានការកើនឡើងដល់ ៣១៩៣៨៣ នៅក្នុងឆ្នាំ ២០១០ ពោលគឺកើនឡើងពី ២៩៦៨០០ នៅក្នុងឆ្នាំ ២០០៩ (សូមមើលរូបភាពទី ៦)។ តែទោះជាយ៉ាងណាក៏ដោយ ចំនួននេះនៅទាបជាងកម្រិតខ្ពស់បំផុតមុនពេលមានវិបត្តិ ដែលកាលនោះមានចំនួន ៣៥២៩៥៥។

រូបភាពទី ៤: ការវិវឌ្ឍនៃកម្លាំងពលកម្ម ២០០០-២០១០ (ពាន់នាក់ គិតជាមធ្យមប្រចាំឆ្នាំ)[៧]




កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ និងកម្មករដែលកំពុងបម្រើការងារបច្ចុប្បន្ននេះ សុទ្ធតែទទួលរងផលប៉ះពាល់ដោយសារឱនភាពនេះ។ បើតាមការសិក្សាមួយរបស់អង្គការពលកម្មអន្តរជាតិ ដែលតាមដានកម្មករនិយោជិតចំនួន ២០០០ នាក់ ធ្វើឡើងនៅក្នុងពេលមានវិបត្តិហិរញ្ញវត្ថុ កម្មករនិយោជិតមួយចំនួន ដែលត្រូវបានបញ្ឈប់ មិនបានទទួលសំណងសម្រាប់ការបញ្ឈប់ពីការងារ ហើយទទួលបានការជូនដំណឹងពីការបញ្ឈប់ការងារក្នុងរយៈពេលខ្លី និងមានការលំបាកក្នុងការស្វែងរកការងារថ្មីធ្វើ។ កម្មករនិយោជិត ដែលនៅមានការងារធ្វើ ក៏ជួបប្រទះនឹងការលំបាកផងដែរ: ចំនួនម៉ោងធ្វើការធម្មតារបស់ពួកគេត្រូវបានកាត់បន្ថយ ហើយពួកគេមានការលំបាកជាងមុនក្នុងការឈប់សម្រាក។ កម្មករនិយោជិតដែលស្ថិតក្នុងស្ថានភាពទាំងពីរនេះ ផ្ញើលុយទៅផ្ទះទៅឱ្យគ្រួសាររបស់ខ្លួនបានតិចជាងមុន ហើយត្រូវកាត់បន្ថយការចំណាយរបស់ខ្លួនលើអាហារ និងការធ្វើដំណើរ។[៨]

រូបភាពទី ៥: ចំនួនរោងចក្រ ខែ មករា ឆ្នាំ ២០១០ ដល់ ខែ ធ្នូ ឆ្នាំ ២០១០[៩]




## ទស្សនវិស័យ និងការឆ្លើយតប

ទស្សនវិស័យសម្រាប់ឧស្សាហកម្មកាត់ដេរ នៅក្នុងប្រទេសកម្ពុជាមានភាពល្អប្រសើរ។ ឧស្សាហកម្មនេះអាចធន់ទៅនឹងព្យុះសង្ឃរាសេដ្ឋកិច្ច ហើយទំនងជានឹងអាចទទួលប្រយោជន៍ពីការផ្លាស់ប្តូរធំៗចំនួន ២ នៅក្នុងឧស្សាហកម្មនេះ។ ទីមួយគឺការកើនឡើងនូវប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិតក្នុងប្រទេសចិន វៀតណាម និងបង់ក្លាដេស។ អ្នកវិនិយោគបរទេសនឹងបន្តរកប្រភពផលិតសម្លៀកបំពាក់ នៅតាមប្រទេសផ្សេងៗ នៅ

[៥] របាយការណ៍សំយោគទី ២៥ ស្តីពីលក្ខខណ្ឌការងារ នៅក្នុងវិស័យកាត់ដេរកម្ពុជា ២០១១

[៦] ក្រសួងពាណិជ្ជកម្ម ២០១១

[៧] ក្រសួងពាណិជ្ជកម្ម ២០១១

[៨] ការសិក្សាតាមដានកម្មករនិយោជិតរបស់វិស័យកាត់ដេរកម្ពុជា ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ខែ មីនា ឆ្នាំ ២០១០

[៩] ក្រសួងពាណិជ្ជកម្ម ២០១១

ពេលដែលប្រាក់ឈ្នួលមានការកើនឡើង។ ខណៈពេលដែលសម្ពាធប្រាក់ឈ្នួល នៅតែបន្តមាននៅក្នុងប្រទេសកម្ពុជា ប្រទេសមួយនេះនៅតែមានប្រាក់ឈ្នួលអប្បបរមាទាបជាងគេ នៅក្នុងតំបន់។[១០] ទីពីរ ប្រទេសកម្ពុជានឹងទទួលបានប្រយោជន៍ពីការផ្លាស់ប្តូរគោលនយោបាយវិធានប្រភពដើមសម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចតួច (LDCs) នៃគំនិតផ្តួចផ្តើម "អ្វីៗគ្រប់បែបយ៉ាង លើកលែងតែអាវុធយុទ្ធភ័ណ្ឌចេញ (Everything But Arms)" របស់សហភាពអឺរ៉ុប ដែលបានចូលជាធរមាន កាលពីដើមឆ្នាំ ២០១១។ ឥលូវនេះ ប្រទេសដែលមានការអភិវឌ្ឍតិចតួចអាចនាំចេញទៅសហភាពអឺរ៉ុប ដោយមិនគិតពន្ធ បើទោះបីជាប្រទេសនោះគ្រាន់តែចូលរួមចំណែក នៅក្នុងផ្នែកខ្លះ នៃការផលិតទំនិញក៏ដោយ។ ប្រទេសកម្ពុជាជាប្រទេសមួយដែលនាំចូលក្រណាត់ទាំងអស់ពីបរទេស នឹងក្លាយជាអ្នកទទួលផលធំជាងគេមួយពីវិធានថ្មីនេះ។ ចុងក្រោយ ការបន្តការឡើងថ្លៃកប្បាស អាចជាបញ្ហាមួយដែរ ប៉ុន្តែសម្ពាធតម្លៃនេះនឹងមានលើប្រទេសផ្សេងក្រៅពីប្រទេសកម្ពុជា ដែលផលិតនូវសម្លៀកបំពាក់ ដែលមានតម្លៃខ្ពស់។

រូបភាពទី ៦: ការវិវឌ្ឍនៃកម្លាំងពលកម្ម ខែ មករា ឆ្នាំ ២០១០ ដល់ ខែ ធ្នូ ឆ្នាំ ២០១០ (ពាន់នាក់)[១១]




ទន្ទឹមគ្នានឹងការទទួលបានប្រយោជន៍ពីកត្តាខាងក្រៅនេះ ប្រទេសកម្ពុជានឹងបន្តមានការរីកចម្រើន នៅខាងក្នុងប្រទេស។ ដៃគូឧស្សាហកម្មមានការប្តេជ្ញាចិត្ត បង្កើនផលិតភាព ខណៈពេលដែលរដ្ឋាភិបាលកំពុងប្រឹងប្រែងកាត់បន្ថយការចំណាយលើថាមពល ដើម្បីធានាយ៉ាងណាឱ្យប្រទេសកម្ពុជាមានឧត្តមភាពប្រកួតប្រជែង នៅក្នុងទីផ្សារសកល។

លើសពីនេះ សហជីព និងរោងចក្រ មានការប្តេជ្ញាចិត្ត ក្នុងការកំណត់មូលដ្ឋានរួមមួយ ដើម្បីធ្វើការកែលំអទំនាក់ទំនងវិជ្ជាជីវៈ។ កិច្ចព្រមព្រៀងទ្វេភាគីថ្មីមួយ ដើម្បីលើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានចុះហត្ថលេខាកាលពីខែ កញ្ញា ឆ្នាំ ២០១០ ដែលមានដាក់បញ្ចូលសេចក្តីសម្រេចចងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រាប់វិវាទសិទ្ធិ។ អនុស្សរណៈយោគយល់គ្នានេះ ក៏បានដាក់បញ្ចូលនូវវិធានការដទៃទៀត ដែលមានគោលបំណងនាំដៃគូឧស្សាហកម្មទាំងអស់ឱ្យធ្វើការរួមគ្នាដើម្បីប្រយោជន៍ឧស្សាហកម្មកាត់ដេរ នៅក្នុងប្រទេសកម្ពុជា។

## *ខែ មេសា ឆ្នាំ ២០១១*

[១០] USAID ២០០៧: ការវិភាគសង្វាក់ផលិតកម្មកម្រិតរោងចក្រនៃឧស្សាហកម្មកាត់ដេរកម្ពុជា ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ២៣។ ប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើនដល់ ៦១ ដុល្លារ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ នៅក្នុងខែ មិថុនា ឆ្នាំ ២០១០។ លើសពីនេះ ប្រាក់បន្ថែមលើប្រាក់ឈ្នួលបានចូលជាធរមាន ដែលផ្តល់នូវប្រាក់រង្វាន់អតីតភាព ប្រាក់រង្វាន់ការងារទៀងទាត់ និងប្រាក់ឧបត្ថម្ភសម្រាប់អាហារពេលធ្វើការថែមម៉ោង នៅក្នុងខែ មីនា ឆ្នាំ ២០១១។

[១១] ក្រសួងពាណិជ្ជកម្ម ២០១១